## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

## រវាង

## រោងចក្រ ថបស៊ីលវើរ លីមីធីត

## និង

## តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ

## រោងចក្រ ថបស៊ីលវើរ លីមីធីត

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ៩ និង ៣០នាទីព្រឹក នៅក្នុងរោងចក្រ ថបស៊ីលវើរ លីមីធីត មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងបច្ចុប្បន្នប្រឈមមុខខ្លាំងនឹងបញ្ហា ជំងឺកូវីត-១៩ ឥវ៉ាន់ដែលបានធ្វើរួចហើយត្រូវអ្នកបញ្ជាទិញមិនទាន់ទទួលតាមការកំណត់ ដោយហាងលក់ទំនិញភាគច្រើននៅបរទេសមិនទាន់បើកទ្វារនៅឡើយទេ ដែលចំណុចទាំងអស់នេះធ្វើអោយផលិតកម្មមួយផ្នែកធំមិនមានការងារធ្វើ តម្រូវអោយមានការព្យួរការងារ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន៣៥៩នាក់ ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនតាមសេចក្តីណែនាំ លេខ០៤៥/២០ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងាររបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

អង្គប្រជុំបានចប់វេលាម៉ោង១១ និង៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន ។

ត្បូងឃ្មុំ.ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០

**តំណាងកម្មករ និង តំណាងសហជីព** **នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត TOP SILVER LIMITED KINGDOM OF CAMBODIA